- **សាំរ៉ាប់ កាម៉ាំង** ត្រគ់ បើក អុញ ហ្វា (អុញ ហៃ ចាំងហាយ្គ) ប៉ាគ់ ទ្រង ឡាង៉ាន់ ភ្សឿ អន់ ហៃ ចាំងហាយ្គ អ្សូគ័ ទី កាណាគ័ ណោះ កាណាគ័ អា វទ្រង លើ ទី កាន ខូច័ ខាច ណោះ ចឹង អ្នុ ជិះ ពឹកៗ លើ តាវ អន់តាន័ ជុង ។



- នៅទីប្រជុំជន ឬកន្លែងផ្លូវឆ្លងកាត់ ចេញចូល ឬមានគេមកពីមុខ អ្នកបើកបរត្រូវប្រើភ្លើងកូដ ដើម្បីកុំឲ្យចាំងភ្នែកគេនាំឲ្យមានគ្រោះថ្នាក់ចរាចរណ៍។
- **ចារ ប៉ាណូស អៀង** លើ ទ្រង ឃ្លង ម៉ុត ឡាច់ លើ ទី ពួ ពឹះ ឡឹង ម៉ាត់ ប៉ាណូស ប៊ិត ត្រគ់ បើក អុញ អន់ កាតេះ ភ៊ឿ ជៃ អន់ ក្លាគ់ ម៉ាត់ ពួ ប្រ៉ៃគ៍ អន់ទៀ ទី កាន ខគ់កាំ។



- មិនត្រូវប្រើសុីផ្លេក្នុងការបើកបរពេលយប់ទេ តែត្រូវប្រើភ្លើងហ្វានិងកូដផ្លាស់គ្នា ដើម្បីជាសញ្ញាសុំផ្លូវជំនួសសុីផ្លេ ។
- ជិះ ម៉ាតូ ឡុត កាមុាំង អូ ត្រគ់ ចុច កាំផ្លេ អុះ ត្រគ់ បើក អុញ ហ្វា/កូត តូវ៍ គួប សោប ភឿ
  សាញ៉ា ប៉ៈ ទ្រង ប៉ាតាង ចុច កាំផ្លេ ។



## ៥- ការបើកជែងគ្នា (វ៉ាគ្នា) (ច្បាប់ចរាចរណ៍ មាត្រា ២០ )

អ្នកបើកបរយានយន្ត ត្រូវមានស្មារតីប្រុងប្រយ័ត និង គិតពីសុវត្ថិភាពជាចំបង

## ៥- កាន ជិះ តាឡ្វះ គួបសោប

ប៉ាណូស ប៊ិត ម៉្វត្ញ ឡុត ត្រគ់ សាំងកៃ ខាក់ ភឿ ជៃ អន់ ទី កាន ខត់កាំ

- អ្នកបើកយានជំនិះគ្រប់ប្រភេទត្រូវជែងគ្នានៅខាងឆ្វេង ។ ប៉ុន្តែអាច ជែងខាងស្តាំបាន បើសិនជាអ្នកបើកបរយាន ដែលត្រូវគេជែងនោះ កំពុងធ្វើសញ្ញាប្តូរទិសខាងឆ្វេងហើយឈប់ ឬត្រៀមដើម្បីបត់ឆ្វេង។

  (សុំមើលសេចក្តីលំអិតនៅចំនុច ងទំព័រ ៧៥-៨១ គោលការណ៍នៃច្បាប់ ចរាចរណ៍សំខាន់ៗ ជាភាសាខ្មែរ ក្នុងសៀវភៅនេះ )

- ប៉ាណូស ប៊ិត ត្រគ់ ជិះ តាឡ្វះ គួបសោប ប៉ែង សាំងអៀា ផា ឡុត ប៉ែង ម៉ាត់ តះ ប៉ែង សាម៉ា លើ តារ ប៉ែង សាម៉ា ពិន តាឡ្វះ ប៉ែង សាំងអៀា ទី ។



- មិនត្រូវបើកជែងគ្នានៅលើផ្លូវដែលមានសញ្ញាហាមជែង ផ្លូវដែលមានកំនូសសញ្ញាពណ៌លឿងជាប់រហូត ផ្លូវទីប្រជុំជន ផ្លូវកែង ផ្លូវស្ពាន  ផ្លូវខូច ផ្លូវកំពុងជួសជុលបានឡើយ លើកលែងតែផ្លូវដែលភាពចង្អៀតខ្លាំង ឬផ្លូវដែលមានឡានទ័ព ឡានពន្លត់អគ្គីសភ័យ ឡានពេទ្យសង្គ្រោះបន្ទាន់ឬឡានជូនដំណើរអ្នកធំដែលត្រូវបានផ្តល់សិទ្ធិអាទិភាព។

- អ្វ ត្រគ់ ប៊ិត តាឡ្វះ គួបសោប ពឹង ទ្រង ឡាក់ កា ទ្រង ទី សាញ៉ា អ្វ អន់ តាឡ្វះ ទ្រង ទី សាញ៉ា ព្ល កាម៉ឹត  ទ្រង ទី ប៉ាណ្វស អៀង  ទ្រង សាឡ្វះ  ទ្រង តាទរ ទ្រង អ៊ិក ល្វ ទ្រង ផះ ព្វ ប៉ាយ៉ាម័  ។ ហះ កា ផា ទ្រង អង់អ្យាគ័ យ៉ឹប លើ ទ្រង ទី ឡ្មុត តាំប៉ាត់ អុញ ឡ្មុត ម៉្វអ្យា ប៉ាទុក ប៉ាណ្វស  អ៊ីគ ល្វ ឡ្មុត ព្វ ជឹន ប៉ាណ្វស ប្រ៉ែគ័ កាន តឹស ណោះ ទី ស៊ិត ចាក អន់ទ្រួល ។








- អាចបើកជែងគ្នាបាន ពេលផុតទីប្រជុំជន ឬផ្លូវដែលមានសុវត្ថិភាព តែងត្រូវគោរពតាមកំនូសសញ្ញាលើទ្រូងផ្លូវ នៅផ្លូវធំទូលាយ ផុតទីប្រជុំជន និងគោរពតាមគំនូសសញ្ញា ពណ៌លឿងដាច់ៗ និង ផ្លាកសញ្ញា ចរាចរណ៍ដោយចុចសុីផ្លេសុំផ្លូវផង។ ប៉ុន្តែ ហាមផ្តាច់កុំជែងនៅខាងស្តាំគេឡើយ លើកលែងតែគេឱ្យភ្លើងសញ្ញាប្តូរទិស ។
- **ចារ ពិន តាឡ្វះ គ្ហបសោប ទី  ផា ហ្វាស ចារ ប៉ាណ្វស អៀង លើ ទ្រង អ្វ ទី កាន ខគ់កាំ ឋះ កា ត្រគ់ ការ៉ុប ហ៊្វប សាញ៉ា ពឹង អន់តើះ ទ្រង ព្ល កាម៉ឹត កាតាច់ៗ ល្វ ហ៊្វប សាញ៉ា ចារ៉ា ច តិគ័ ទឹប ចុច កាំផ្លេ ប៉រ់ ទ្រង តិគ័ ។ ឋះ កា ត្រគ់ តាឡ្វះ តែង សាម៉ា ព្វ លើយ ផា ប៉ប័ ព្វ បើក អុញ សាញ៉ា ចឹង តះ ទ្រង ពិន អ្វ ត្រគ់ តាឡ្វះ អន់ទ្រួល ឡឹង ព្វ អុះ ។**





## ៦- សុជីវធម៌ ក្នុងការបើកបរ

អ្នកបើកបរយានយន្ត ត្រូវមានស្មារតីប្រុងប្រយ័ត និងគិតពីសុវត្ថិភាពជាចំបង

## ៦- កាន អ្នុ ហ៉ៃ អ្នុ ថយ គួបសោប ផះ ជិះ ម៉្វត្វ ឡុត

ប៉ាណ្វស ប៊ិត ម៉្វត្វ ឡុត ត្រគ់ សាំងក៉ែ ខាក់ ភឿ ជែ អន់ ទី កាន ខគ់កាំ

- អ្នកបើកបរ ត្រូវគោរពសិទ្ធិមនុស្ស និងច្បាប់នៃការបើកបរ

  ប៉ាណ្វស ប៊ិត ម៉្វត្វ ឡុត ត្រគ់ ការ៉ុប ស៊ុត ប៉ាណ្វស ល្វ ចាបាប់ ជិះ ម៉្វត្វ ឡុត

- អ្នកបើកបរ ត្រូវតាំងចិត្តគោរពច្បាប់ចរាចរណ៍ជានិច្ច

  ប៉ាណ្វស ប៊ិត ម៉្វត្វ ឡុត ត្រគ់ អ្យក់ ពុត ចៃគ ការ៉ុប ចាបាប់ ចារ៉ា ច កាខាក់

- អ្នកបើកបរ ត្រូវគិតពីសុវត្ថិភាពចរាចរណ៍ជាចំបង រវាងខ្លួនឯង និងអ្នកដទៃ

  ប៉ាណ្វស ប៊ិត ម៉្វត្វ ឡុត ត្រគ់ ឃឹត ជែ អន់ ទី កាន ខគ់កាំ ទឹប ឡាកោ តាំងឡា ល្វ ព្វ អន់ទៀគ

- អ្នកបើកបរ ត្រូវមានចិត្តធូន់ ចេះយោគយល់គ្នា ក្នុងការបើកបរ

  ប៉ាណ្វស ប៊ិត ម៉្វត្វ ឡុត ត្រគ់ ប្រ៉េគ៌ ពុត ឡាអត់ ល្វ អត់ សាំរ៉ាញ៉ុំ គួបសោប ផះ ជិះ ម៉្វត្វ ឡុត

- អ្នកបើកបរ គួរកុំចង់ឈ្នះគ្នាទៅវិញទៅមក តែគួរយកឈ្នះលើបញ្ហាវិញ

  (ជោគជ័យក្នុងការបើកបរ)

  ហងប៉ាណ្វស ប៊ិត ម៉្វត្វ ឡុត អ្វ ត្រគ់ ប៊ុច ប្រ៉ាល់ អឺស ប្រាល់ អាញ៉ុ អុះ ប្រ៉េគ៌ ជែ អន់ ទី កាន ខគ់កាំ ទិឌ្វ

## ង/ គោលការណ៍នៃច្បាប់ចរាចរណ៍សំខាន់ៗ

## ង/ សារ សាំខាន់ៗ ពឹង ចាបាប់ ចារ៉ា ច

- ហាមពិសាជាតិស្រវឹងដែលមានអត្រាជាតិអាកុលចាប់ពី ០,២៥ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥ ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ។ (ច្បាប់ចរាចរណ៍ មាត្រា៩)
  **អ្វ អន់ អែត តាពៃ ឡាក់ ទី ជៀត អាកុល ០.២៥ មីលីក្រាម កាណុង ១ លីត ខ្យាល លើ លើន ឡឹង ០.៥ ក្រាម កាណុង ម៉ោញ លីត ផាម ។**
- ការបើកបរយានជំនិះគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ស្តាំជានិច្ច ។
  **ប៉ាណូស ប៊ិត ម៉ូតូ ឡុត គ្រឹប នែវ កាណុង ប៉ាថេត កាំពូចៀ ត្រត់ បើក ចាក ប៉ែង សាម៉ា លើយ ។**
- អ្នកបើកបរមិនត្រូវបើកបរទន្ទឹមគ្នានៅលើទ្រូងផ្លូវ ឬគន្លងផ្លូវតែមួយបានទេ (ច្បាប់ចរាចរណ៍មាត្រា១៤)

  **ប៉ាណូស ប៊ិត ម៉ូតូ ឡុត អ្វ ត្រត់ ជិះ ត្រីត អន់ត្រីតៗ គួបសោប ពឹង ទ្រង សាល្វង លើ  អុះ**
- នៅក្នុងទីប្រជុំជន :  **ហះ ចារ ទី ប៉ាណូស អៀង:** (ច្បាប់ចរាចរណ៍ មាត្រា១៧)
  - អ្នកបើកបរត្រូវប្រើល្បឿនអតិបរមា ៣០គីឡូម៉ែត្រក្នុងមួយម៉ោង

    ចំពោះទោចក្រយានយន្ត  **ប៉ាណូស ប៊ិត ម៉ូតូ តុត ប្រ៉ាល់ ៣០ កាឡូ ម៉ិត កាណុង ១ មង ។**
  - អ្នកបើកបរត្រូវប្រើល្បឿនអតិបរមា៤០គីឡូម៉ែត្រក្នុងមួយម៉ោង  ចំពោះរថយន្តគ្រប់ប្រភេទ។
    **ប៉ាណូស ប៊ិត ឡុត គ្រឹប នែវ ត្រត់ ជិះ តុត ប្រ៉ាល់ ៤០ កាឡូ ម៉ិត កាណុង ១ មង ។**
- **អ្នកបើកបរត្រូវបន្ថយល្បឿន ក្នុងករណីដូចខាងក្រោម** : (ច្បាប់ចរាចរណ៍ជំពូក៣ មាត្រា១៨)
  **ប៉ាណូស តាកុង ម៉ូតូ ឡុត ត្រត់ ជិះ ពឹកៗ វ៉ិច លូ *តែង អន់តេះ អ៉ា***    :

  ១-នៅពេលជៀសគ្នា នៅលើផ្លូវចង្អៀត ។  **ផះ វ៉េះ គួបសោប ពឹង ទ្រង អង់អ្យាត៉ ។**

  ២-នៅពេលជៀសឬជែងរថយន្តដឹកជញ្ជូនអ្នកដំណើរឬរថយន្តដឹកជញ្ជូនកុមារដែលកំពុងឈប់ដាក់អ្នកដំណើរ ឬកុមារឡើងចុះ ។
  **ផះ វ៉េះ លើ តាឡូះ  ឡុត ប៉ាទុក ប៉ាណូស  លើ ឡុត ប៉ាទុក កុម៉ា ផះ តាវ ជីវ ហាវ អ្យក់ ប៉ាណូស លើ កុម៉ា ។**

  ៣-ពេលទៅជិតដល់ស្ពាន ឬជិតដល់ផ្លូវរថភ្លើងឆ្លងកាត់ ។
  **ផា ក្យាម៉ំ ចឹង ទឹល តាទវ លើ ទ្រង ឡុត អុញ (រថភ្លើង) ចាក ឃ្លង**

  ៤-នៅពេលអាកាសធាតុមិនល្អ ដែលមិនអាចមើលឃើញបានឆ្ងាយ និងច្បាស់ ។
  **ផា ប៉្លែង អ្វ សូវ ដាត់ ហៃ គួបសោប អ្វ ប៉ប៉ំ លើ អ្វ សាឡូះ**

  ៥-នៅពេលប្តូរទិសចរាចរណ៍ ។  **ផា ប៊ុច តះ ឡាំ ប៉ែង ណោះ ប៉ែង អា ។**

  ៦-នៅត្រង់ផ្លូវបត់ ផ្លូវកោង ផ្លូវរអិល ផ្លូវប្រសព្វ ឬរង្វង់មូល ។
  **ហះ ទ្រង តះ ទ្រង កោត ទ្រង រ៉ាផល់ ទ្រង តះ សាំងអ្សៀ សាម៉ា លើ ទ្រង តាវ៉ ម៉ូល៉ ។**

៧-នៅពេលជិតដល់ទួលខ្ពស់ ឬពេលចុះចំណោត។ **ផា ក្យាម៉ ចឹង ទឹល ទ្រង ហារ ច្រាំង ជឺរ ច្រាំង ។**

៨-នៅពេលជៀស ឬជែងក្បួនយានកំពុងឈប់ ឬនៅពេលជៀស ឬជែងក្បួនដង្ហែផ្សេងៗ។

**ចារ វេះ លើ ចារ តាឡូះ កា ឡុត ផះ តារ លើ តាឡូះ អន់ទ្រួល ឡឹង ឡុត អន់ទ្រួល ពូ ជិះ ប៉ាន់ទយ អៀង។**

៩-នៅពេលមានវត្ថុច្រងេងច្រងាង ឬមានផ្ទះសង់ច្រើនកៀកជាប់ទ្រូងផ្លូវ ។

**ផា ទី កាណាគ៉ រទ្រង សាំងរីគ សាំងរ៉ុ លើ ទី ហិ អៀង ចានែង ទ្រង ។**

១០-ក្នុងគ្រប់ករណី ដែលមានផ្លាកសញ្ញាឱ្យបន្ថយល្បឿន ឬសញ្ញាគ្រោះថ្នាក់ ។

**ផា ទី ហ៊្វប សាញ៉ា អន់ ជិះ ពឹកៗ លើ ហ៊្វប សាញ៉ា ខគ់កាំ។**

១១-កាលណាមានយានជំនិះរបស់នគរបាល យោធា ឬអាវុធហត្ថ យានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ និងយានយន្ត ដែលមានបន្លឺសូរស័ព្ទ ឬភ្លើងសញ្ញាអ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវ បន្ថយល្បឿន ហើយបើកអែបមកខាងស្តាំ បើចាំបាច់ត្រូវឈប់នៅកៀន បំផុតដែលអាចធ្វើទៅបាន ដើម្បីសម្រួលផ្លូវឱ្យយានទាំងនេះធ្វើដំណើរទៅមុខដោយសុវត្ថិភាព។

**ផា ទី ឡុត ប៉ាលិះ តាហាន ប៉េអឹម ឡុត តាំប៉ាត់ អុញ ឡួត ម្ហួត ម៉្ញអ្យា អ្យក់ ប៉ាណ្វស អឹគ ឡុត ពួ ចៃគ សារ៉ែន លូ ឡុត ពួ ចៃគ អុញ សាញ៉ា ពិន ត្រគ់ ប៊ិត ពឹកៗ ប៉ែង សាម៉ា លើយ ផា តងកាន តារ ត្រគ់ តារ ហះ តែង ទ្រង អន់ ឡុត ពួ ណោះ ចាក អន់ទ្រួល ភឿ ជែ អន់ ទី កាន ខគ់កាំ។**

១២-នៅកន្លែងមានសាលារៀនដែលមានទីតាំងស្ថិតនៅក្បែរ ផ្លូវមិនលើសពី៥០ម៉ែត្រ។

**៥០ ម៉ិត ក្យាម៉ សាឡា ហៀន រទ្រង ពិន ត្រគ់ ជិះ តាគ់ អំពឹក ។**

- យានជំនិះមួយដែលធ្វើចរាចរណនៅពីក្រោយយានជំនិះមួយផ្សេងទៀត ត្រូវរក្សាទុកចន្លោះសុវត្ថិភាពគ្រប់គ្រាន់ដើម្បីជៀសវាងការប៉ះទង្គិចនៅពេលដែលយានជំនិះខាងមុខបន្ថយល្បឿនឬឈប់ដោយចៃដន្យ ។ (ច្បាប់ចរាចរណ៍ មាត្រា១៩)

**ពិន ត្រគ់ ជិះ ម៉ូតូ ឡុត អន់ ចាំងហាយ្គ ឡឹង បក ចាក អន់ទ្រួល លូ ត្រគ់ ប៉ាហើយ ទ្រង ភឿ ជែ អន់ កាន់តើស គួបសោប ផា បក់ អន់ទ្រួល ជិះ តាគ់ អំពឹក លូ តារ ពិន អ្វូ អ្នុ អន់តគ់ ។**

- **ក្នុងការជៀស : កាន វេះ** :(ច្បាប់ចរាចរណ៍ជំ មាត្រា២១)

១-អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវជៀសគ្នាដោយប្រកាន់ស្តាំដៃរៀងៗខ្លួន ។

**ប៉ាណ្វស ប៊ិត ម៉ូតូ ឡុត គ្រឹប នែរ ត្រគ់ វេះ ប៉ែង សាម៉ា ពឿ សាម៉ា អ៊ែ ។**

២-នៅមុនពេលជៀសគ្នា អ្នកបើកបរទាំងសងខាង ត្រូវជឿជាក់ថាការជៀសគ្នានេះមិនបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីឡើយ ។

**អន់ទ្រួល ចឹង វេះ ឡឹង គួប សោប ប៉ាណ្វស ប៊ិត ទិ ញៀរ ប៉ែង អ្នុ អន់តគ់ ផា កាន វេះ អា អ្វូ ប្រ៉េគ៉ អន់ ទី កាន ខគ់កាំ អុះ ។**

៣-ដើម្បីជៀសគ្នាអ្នកបើកបរត្រូវអែបខាងស្តាំដៃរៀងៗខ្លួនដោយទុកផ្លូវទំនេរនៅឆ្វេងដៃរបស់ខ្លួនឱ្យបានធំបំផុតដែល អាចធ្វើ ទៅបាន ។

**ប៉ាណូស ប៊ិត ម៉្វត្វ ឡុត ត្រគ់ វេ៉ះ គ្ហបសោប ហះ ចាំនែង ទ្រង ប៉ែង សាម៉ា ពឿ សាម៉ា អ៊ែ ប្រ៉គ៍ នីចមំ គម ទ្រង សាំងអៀា តី អន់ ឡាហោង ។**

៤-ពេលជៀសគ្នានៅលើផ្លូវចង្អៀត ឬនៅលើផ្លូវដែលអាចមានគ្រោះថ្នាក់ អ្នកបើកបរត្រូវបន្ថយល្បឿនរៀងៗខ្លួន ។ ក្នុងករណីចាំបាច់យានជំនិះទាំងពីរត្រូវឈប់ ហើយបើជាយានជំនិះប្រភេទដូចគ្នា យានជំនិះណាចង់ទៅមុន ត្រូវធ្វើសញ្ញាសុំផ្លូវដោយលើកដៃឬដោយស៊ីផ្លេនៅពេលថ្ងៃឬប្រើភ្លើងហ្វាកូតជាសញ្ញានៅពេលយប់ ហើយរង់ចាំយានជំនិះដែលមកពីមុខបញ្ចេញសញ្ញាយល់ព្រមឱ្យទៅមុនទើបធ្វើដំណើរទៅបាន ។ ប៉ុន្តែបើសិនជាយានប្រភេទខុសគ្នាអ្នកបើកបរយានធុនធំត្រូវទុកផ្លូវឱ្យយានដែលមានទំហំតូចជាងយានរបស់ខ្លួនធ្វើដំណើរទៅមុន ។

**ផា វេ៉ះ ទ្រង អង់អ្យាគ៍ លើ ទ្រង ទី កាន ខគ់កាំ ប៉ាណូស ប៊ិត ឡុត ត្រគ់ ជិះ អន់ ពឹក ។ ផា ពិន តងកាន ចាក អន់ទ្រួល កាដារ់ ពិន ត្រគ់ លើក តី លើ កាំផ្លេ ។ ផា កាម៉ាំង ពិន បើក អុញ សាញ៉ោ ប៉ារ់ ទ្រង កេះណោះ ពិន ក្យាគ់ ហៃ បក់ អន់ទ្រួល សាញ៉ោ អន់ ពិន តាឡ្វះ ញ៉ោ អ្វ ។ ផា ឡុត តីស គែង ម៉ាត់ ចាក អន់ទ្រួល ត្រគ់ អន់ ឡុត ចិ ចាក អន់តឹគ តាឡ្វះ ចាក អន់ទ្រួល ។**

៥-ពេលជៀសគ្នានៅលើផ្លូវតូចដែលបរបានយានជំនិះតែមួយហើយមានកន្លែងមួយដែលអាចជៀសគ្នាបានយានជំនិះណាដែលមកដល់កន្លែងនេះមុន ត្រូវឈប់រង់ចាំនៅកន្លែងនេះដើម្បីទុកឱ្យយានជំនិះមួយទៀតជៀសបានស្រួល ។

**ផា ពិន ប៊ិត ទ្រង ចិ ឡុត ចាក បគ៍ ដឹង ម៉ោញ ណោះ ពិន ត្រគ់ វេ៉ះ តាវ ម៉ោញ ចារ ក្យាគ់ អន់ ឡុត ណោះ ចាក វ៉ាំច់ ហិ ណោះ ពិន ចាក ទី ។**

៦-ពេលជៀសគ្នានៅលើផ្លូវចោតហើយចង្អៀត យានជំនិះ ចុះចំណោតត្រូវឈប់ ដើម្បីទុកឱ្យយានជំនិះឡើង ចំណោតទៅមុន ។

**ចារ វេ៉ះ ហះ ច្រាំង ល្វ ទ្រង អង់អ្យាគ៍ បក់ ផះ ជឺរ ត្រគ់ តាវ បក់ ហាវ ចាក អន់ទ្រួល ។**

៧-ក្នុងការជៀសគ្នា យានជំនិះណាមើលឃើញ នៅលើចំណែក ផ្លូវរបស់ខ្លួនមានឧបសគ្គ ដូចជាផ្លូវខូច ឬមានយានជំនិះឈប់ស្ងៀមយានជំនិះនោះត្រូវឈប់ដើម្បីទុកឱ្យយានជំនិះ មួយទៀតទៅមុន ។

**ផា ពិន ប៊ិត ឡុត ប៉បំ ទ្រង ប៉ាគ់ ម៉ាត់ ទី កាន ខូចំ ខាច ឡាក់ កា ទ្រង ខូចំ លើ ឡុត ម៉្វត្វ ចំ តាវ ម៉ោញ ចារ ណោះ ពិន ត្រគ់ តាវ អន់ បក់ អន់ទៀគ ណាវ្គ ចាក អន់ទ្រួល ។**

៨-នៅលើស្ពានចង្អៀត ដែលបើកបរបានតែរថយន្តមួយ គ្រឿងរថយន្តធុនធំត្រូវទុកសិទ្ធិឱ្យរថយន្តធុនស្រាលទៅមុន ។

**កាណុង តាទរ អង់អ្យាគ៍ ចាក បគ៍ ដឹង ឡុត ម៉ោញ កាតុ ឡុត តីស តាវ អន់ ស៊ុត កា ឡុត ចិ ចាក អន់ទ្រួល។**

១០-មនុ ពេលជៀសគ្នា នៅពេលយប់ក្រៅទីប្រជុំហើយគ្មានចង្កៀងអគ្គិសនី យានជំនិះទាំងពីរត្រូវបិទភ្លើងហ្វាហើយបើកភ្លើង កូតវិញ ។

**ចារ ពិន វេះ គួបសោប កាម៉ាំង ចារ អូ ទី ប៉ាណូស លូ អូ ទី អុញ អាគីស សានី រទេង ម៉ូតូ ឡុត ទិ ពៀរ បែ៉ង ត្រត់ តាំប៉ាត់ អុញ ហ្វា កេះណោះ បើក អុញ កួត ណាវ៉ុ ។**

- គ្រប់អ្នកបើកបរនៅពេលទៅជិតដល់ផ្លូវប្រសព្វ ត្រូវបន្ថយល្បឿននិងពិនិត្យមើលចលនាចរាចរណ៍ នៅលើទ្រូងផ្លូវដែលខ្លួនត្រូវឆ្លងកាត់នោះហើយត្រូវធ្វើដំណើរឆ្លងកាត់ដោយប្រុងប្រយ័តបំផុត។ (ច្បាប់ចរាចរណ៍ មាត្រា២២)

**ប៉ាណូស ប៊ិត ទិខូ ផា ក្យាម៉ ចឹង ទឹល ទ្រុង តះ កេះ ត្រត់ ជិះ ពីក។ លូ ប៉ានិត ហៃ ម៉ូតូ ឡុត ពីង ទ្រុង កេះណោះ ឃ្លង ទ្រុង ត្រត់ សាំងកៃ ខាក់ ។**

- ក្នុងការឈប់ និងការចត នៅលើផ្លូវថ្នល់ : (ច្បាប់ចរាចរណ៍ជំពូក៣ មាត្រា២៤)

  គ្រប់យានជំនិះ ដែលឈប់ ឬចត មិនត្រូវបង្កឱ្យរំខានដល់ យានជំនិះផ្សេងៗទៀតដែលកំពុងធ្វើចរាចរណ៍។ មុននឹងផ្លាស់ប្តូរទិសដៅនៃយានរបស់ខ្លួន ដូចជាក្នុងការបត់ឆ្វេង ឬបត់ស្តាំពេលប្តូរគន្លងផ្លូវ ពេលអែបខាងដើម្បីឈប់ឬចត អ្នកបើកបរត្រូវបន្ថយល្បឿន និងត្រូវជឿជាក់ជាមុនថាមិនបណ្តាលឱ្យមានគ្រោះថ្នាក់ ហើយត្រូវឱ្យសញ្ញាយ៉ាង ច្បាស់ និងគ្រប់គ្រាន់ជាដំណឹងដល់អ្នកដទៃដែលកំពុងប្រើប្រាស់ផ្លូវនោះដែរ។

  **កាន តាវ លូ ចៃត ម៉ូតូ ឡុត ពីង ទ្រុង ត្រឹប ម៉ូតូ ឡុត ឡាក់ ចៃត លូ តាវ ពីង ទ្រុង អូ ត្រត់ ប្រ៉ត់ អន់ ប៉ាណាប កា បក់ អន់ទៀត។ ឡាក់ ចាក ពីង ទ្រុង ដេល អុះ ។ អន់ទ្រួល ចឹង វេះ សាំងអៀ្យ សាម៉ា ឃ្លង ឡាំ ប៉ាត់ តែង ភឿ ចឹង តាវ ប៉ាណូស ប៊ិត ត្រត់ ជិះ ពីក។ លូ អន់ សាញ៉ា ឡាក់។ ភឿ ដៃ អន់ កាន់តើស ពូ ផះ ចាក ទ្រុង ណោះ ដេល ។**

- **ការបត់ឆ្វេង** : (ច្បាប់ចរាចរណ៍ជំពូក៣ មាត្រា២៦)
  - មុននឹងធ្វើការបត់ឆ្វេង ត្រូវក្រឡេកមើលក្រោយតាមកញ្ចក់មើលក្រោយ ពិសេសតាមកញ្ចក់ខាងឆ្វេង ដើម្បីឱ្យដឹងទីតាំង និងចលនាចរាចរណនៅពីខាងក្រោយ
  - ត្រូវធ្វើសញ្ញាប្តូរទិសទៅខាងឆ្វេងឱ្យបានចម្ងាយគ្រប់គ្រាន់ពីកន្លែងដែលត្រូវបត់ និងបន្ថយល្បឿន ហើយបើគ្មានឧបសគ្គអ្វីទេត្រូវបើកអែបគំនូសបង្ខតកណ្តាលទ្រូងផ្លូវ
  - នៅពេលរៀបនឹងបត់ឆ្វេង ត្រូវមើលឆ្វេង ស្តាំ និងមើលឆ្វេងម្តងទៀតពិសេសមើលចរាចរណយានមកពីទិសផ្ទុយ។ បើផ្លូវទំនេរត្រូវបត់ដោយប្រុងប្រយ័ត្ន ពិសេសចំពោះថ្មើរជើងដែលកំពុងឆ្លងកាត់។ បើផ្លូវមិនទំនេរត្រូវរង់ចាំដោយ ទុកឱ្យអ្នកបើកបរយានដែលមកពីទិសផ្ទុយ និងមកពីទិសខាងស្តាំទៅមុន ។
  - ការបត់ឆ្វេងត្រូវធ្វើតាមបែបស្មៀវស្តាំ គឺបត់ពីក្រោយចរាចរណយានមកពីទិសផ្ទុយ លើកលែងតែមានការណែនាំ ពីនគរបាលចរាចរណ៍ ។

- **កាន តះ សាំងអៀ្យ :**
  - **អន់ទ្រួល ចឹង តះ សាំងអៀ្យ ត្រត់ កាលែង កែង តែង អង់កក់ ពួយ សាម៉ឹល ខាក់ អ៊ែ សាម៉ឹល សាំងអៀ្យ ភឿ អន់ អ្ហ អន់តក់ ផា តែង អង់កក់ ទី ពូ ជិះ ម៉ូតូ ឡុត ញ៉ា អូ ។**

- ផា តះ សាំងអៀា ត្រគ់ ប្រ៉គ័ សាញ៉ា អន់ ពួ អ្ន ឡឹង ចាំងហាយ្គ ឡឹង ចារ ពិន ចឹង តះ លូ ប៉ាន់ថយ អន់ ពឹក។ ផា អ្ន ទី សារ ញ៉ា កើត ពឹះ ត្រគ់ រ៉េះ ប៉ៃង សាំងអៀា ខយ។ ពួយ សាញ៉ា ពួ រ៉ៃក ពឹង អន់តិគ័ ទ្រង ។
- ផា ក្យាម័ ចឹង តះ សាំងអៀា ត្រគ់ ហៃ ប៉ៃង សាំងអៀា សាម៉ា កេះណោះ ហៃ សាំងអៀា ណារ្គ ខាក់ អ៊ៃត្រគ់ ហៃ បក់ ចាក ទ្រង តាតិគ័ ។ ផា ទ្រង អ្ន ទី ម៉្វត្វ ឡុត ត្រគ់ តះ សាំងកៃ ប៉ាឡឹង។ ខាក់ អ៊ៃ ត្រគ់ ម៉្វត្វ ផះ ឃ្លង ។ ផា ទី ពួ ម៉្វត្វ ឡុត អៀង ត្រគ់ អន់ បក់ ពឹះ ឡឹង ទ្រង អន់ទៀគ។ លូ បក់ ពឹះ ឡឹង សាម៉ា ចាក អន់ទ្រួល ។
- កាន ប៉ៃង សាម៉ា ត្រគ់ រ៉ៃរ ប៉ៃង សាម៉ា ត្រគ់ អន់តឹគ ឡឹង បក់ ពឹះ ឡឹង តាង ឡឹង ពិន ហះ កា ត្រគ់ ចាក ទ្រង អន់ទៀគ។ ដេល ផា ទី មួត ប៉ាលិះ ចារ៉ា ច អន់តគ់ កា ពិន ។

## ➢ ការជែង

ក្នុងការជែង អ្នកបើកបរត្រូវអនុវត្តដូចខាងក្រោម :

១-អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវជែងគ្នានៅខាងឆ្វេង ។ ប៉ុន្តែអ្នកបើកបរអាចជែងខាងស្តាំបាន បើសិនជាអ្នកបើកបរយាន ដែលត្រូវគេជែងនោះ បាននឹងកំពុងធ្វើសញ្ញាប្តូរទិសខាងឆ្វេង ហើយ ឈប់ ឬត្រៀមដើម្បីបត់ឆ្វេង ។

២-មុននឹងជែង អ្នកបើកបរត្រូវដឹងច្បាស់ថា ការជែងនេះ ឥតបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីឡើយ ដោយ ត្រូវអនុវត្តដូចខាងក្រោម :

ក-ឃើញច្បាស់ថា នៅខាងមុខ**គ្មាន**ឧបសគ្គហើយអាចបរចូលទៅក្នុងចរន្តចរាចរណ៍ប្រក្រតីវិញ បាននៅពេលជែងរួច ដោយមិនរំខានដល់ការធ្វើចរាចរណរបស់អ្នកដទៃឡើយ ។

ខ-**គ្មានអ្នក**បើកបរយានជំនិះ ណាមយួ ដែលនៅពីក្រោយខ្លួនចាប់ផ្តើមសុំជែងខ្លួន ។

គ-**គ្មាន**ឱ្យសញ្ញាសុំជែងយានផ្សេងទៀត ពីអ្នកបើកបរយានជំនិះខាងមុខខ្លួន ។

ឃ-ត្រូវដឹងច្បាស់ថា ល្បឿនសមាមាត្រ រវាងយានទាំងពីរអាចឱ្យជែងក្នុងរយៈពេលខ្លីបំផុតបាន។

ង-ត្រូវធ្វើសញ្ញាសុំជែង ដោយប្រើសញ្ញាប្តូរទិសខាងឆ្វេងហើយក្នុងករណីចាំបាច់ត្រូវប្រើបន្ថែមភ្លើងកូត ហ្វាឆ្លាស់គ្នានៅពេលយប់ ឬស៊ីផ្លេនៅពេលថ្ងៃ លើកលែងតែក្នុងទីប្រជុំជន ដែលការប្រើប្រាស់ស៊ីផ្លេ សុំជែងត្រូវហាមឃាត់ ។

ច-ត្រូវដឹងច្បាស់ថា អ្នកបើកបរយានជំនិះខាងក្រោយ និងខាងមុខ បានដឹងអំពីការសុំជែងរបស់ខ្លួនហើយ ។

៣-អ្នកបើកបរយានខាងមុខនៅពេលដឹងថាយានខាងក្រោយសុំជែងត្រូវពិនិត្យចំណែកផ្លូវខាងមុខខ្លួន បើ**គ្មាន** ឧបសគ្គអ្វីទេ ត្រូវឱ្យសញ្ញាប្តូរទិសខាងស្តាំ ឬលើកដៃឆ្វេងឡើងលើបត់ទៅស្តាំ និងបន្ថយល្បឿនអែប

ទៅខាងស្តាំ ជាសញ្ញាឱ្យអ្នកបើកបរយានខាងក្រោយដែលសុំជែងដឹងថា អាចជែងបាន ។
ក្នុងករណីអ្នកបើកបរខាងមុខពិនិត្យឃើញថា នៅចំណែកផ្លូវ ខាងមុខខ្លួនមិន ទំនេរ ឬមានឧបសគ្គ ត្រូវធ្វើសញ្ញាប្តូរទិសខាងឆ្វេងឬលាតដៃឆ្វេងសន្ធឹងត្រង់ទៅខាងក្រៅ ជាសញ្ញាឱ្យដឹងថា ការជែងពុំទាន់អាចធ្វើទៅបានទេ ។

៤-នៅពេលជែង ត្រូវបង្កើនល្បឿន និងទុកចន្លោះឃ្លាតពីគ្នាយ៉ាងតិច ១ម៉ែត្រ ។

៥-នៅលើទ្រូងផ្លូវគ្មានគំនូសបង្ហូត អ្នកបើកបរយានអាចជែង ដោយប្រើប្រាស់ទ្រូងផ្លូវ មួយ ចំហៀងទៀតបាន លុះត្រាតែទង្វើនេះមិនធ្វើឱ្យមានគ្រោះថ្នាក់ ឬរំខានដល់យានដែលបើកបរផ្ទុយនឹងទិសរបស់ខ្លួន ។

៦-នៅពេលជែងផុត អ្នកបើកបរត្រូវធ្វើសញ្ញាប្តូរទិសខាងស្តាំវិញ ដើម្បីឱ្យដំណឹងថាខ្លួនត្រូវចូលក្នុងចរន្តចរាចរណរបស់ខ្លួនវិញ។

៧-ក្នុងករណីទ្រូងផ្លូវ មានគន្លងផ្លូវច្រើនតាមទិសចរាចរណ៍តែមួយសម្រាប់ទិសដៅផ្សេងគ្នា យានស្ថិតនៅគន្លងណាមួយបើកបរលឿនជាងយាននៅគន្លងណាមួយទៀតមិនចាត់ទុកជាការជែងឡើយ ។

## ➢ ហាមជែងគ្នា នៅក្នុងករណីខាងក្រោម :

- ជែងគ្នាជាបីជួរ (ជែងលើរថយន្តដែលកំពុងជែងគ្នា)
- នៅកន្លែងមានសញ្ញាហាមជែង
- នៅត្រង់ផ្លូវកោង ឬផ្លូវឡើងទួល លើកលែងតែការជែងនេះអាចទុកឱ្យផ្នែកទ្រូងផ្លូវខាងឆ្វេងគំនូសបង្ហូតកណ្តាលនៅទំនេរបាន
- នៅជិត ឬត្រង់ផ្លូវបត់ ផ្លូវខ្វែង ផ្លូវរអិល
- នៅត្រង់កំពូលផ្លូវចោត ផ្លូវតូចចង្អៀត ឬផ្លូវដាក់សញ្ញាបន្ថយល្បឿន
- នៅលើស្ពាន ឬពេលចុះចំណោត
- នៅកន្លែងការដ្ឋាន
- នៅជិត ឬត្រង់កំណាត់ផ្លូវ ដែលទុកសម្រាប់ថ្មើជើងឆ្លងកាត់
- នៅផ្លូវក្រោមស្ពាន ឬផ្លូវក្នុងរូង
- នៅពេលមើលឃើញមិនច្បាស់ ដូចជាពេលភ្លៀងខ្លាំងឬចុះអ័ព្ទខ្លាំង ឬដីហុយខ្លាំង
- នៅជិត ឬត្រង់ផ្លូវថ្នល់កាត់ផ្លូវរថភ្លើងដែលគ្មានរបាំង
- នៅលើផ្លូវដែលមានទឹកលិច ។

## ➢ កាន តាឡ្វះ អន់ទ្រួល

**កាណុង កាន តាឡ្វះ អន់ទ្រួល ប្រ៉ែគ៎ ពួយ តែង អន់តេះ អា :**

១-ប៉ាណ្វស ប៊ិតគ្រឹប នែវ ត្រគ់ តាឡ្វះ បៃិង សាំងអៀ្យា ។ ហះ កា ពិន តាឡ្វះ សាម៉ា ទី ដេល ផា ព្វ ណោះ ផះ ចឹង តះ ឡាំ បៃិង សាំងអៀ្យា លើ តាវ លើ ទ្រៀម តះ បៃិង សាំងអៀ្យា ។

២-អន់ទ្រួល ចឹង តាឡ្វះ ប៉ាណ្វស ប៊ិតត្រគ់ អ្ន អន់តក់ កាន តាឡ្វះ ណោះ អ្វ ប្រ៉ែគ៎ អន់ កា ខគ់កាំអុះ ត្រគ់ ប្រ៉ែគ៎ ពួយ អន់តេះ ៉ អា :

ក-ផា តែង ម៉ាត់ អ្វ ទី សារ ញ៉ា កើត ពឹះ កេះណោះ តះ ម៉ុត ពឹង ទ្រង អន់ខ្វ ល្វ ព្វ ប្រាន ណារ្គ ហះ កា អ្វ ត្រគ់ ប្រ៉ែគ៎ អន់ ព្វ អន់ទៀគ ប៉ាណាប ញូន ពិន អុះ ។

ខ-អ្វ ទី ប៉ាណ្វស ប៊ិតម៉្វត្វ ឡុត ចំ ម៉ោញ អ្វែ បៃិង អង់កក់ ពិន ផះ ចឹង ប៉ៃរ តាឡ្វះ ចាក អន់ទ្រួល ។

គ-អ្វ ទី តាំបាង សាញ៉ា ប៉ៃរ តាឡ្វះ ឡឹង ម៉្វត្វ ឡុត អន់ទៀគៗ ឡាក់ ជិះ បៃិង ម៉ាត់ ពិន ។

ឃ-ត្រគ់ អ្ន អន់តក់ ផា កាន តាឡ្វះ អន់ទ្រួល ពឹក ប្រ៉ាល់ សាម៉ើ គួបសោប អ្វ ចាំងហាយ្គ អុះ ។

ង-ត្រគ់ ប៉ៃរ សាញ៉ា តាឡ្វះ អន់ទ្រួល តែង សាំងអៀ្យា ផា តងកាន ខាក់ ត្រគ់ បើ អុញ កូ្វត អុញ ហ្វា ប៉ាន់ធែម ណារ្គ ផា កាម៉ុាំង លើ ចុច កាំផ្លេ សាំរ៉ាប់ កាដារ់ ផា ហះ ចារ ទី ប៉ាណ្វស អៀ ព្វ អ្វ អន់ ចុច កាំផ្លេអុះ។

ច-ត្រគ់ អ្ន អន់តក់ ផា បក់ តែង ម៉ាត់ ល្វ បៃិង អង់កក់ អ្ន អន់តក់ កេះ កា ពិន ប៉ៃរ តាឡ្វះ អន់ទ្រួល ណោះ។

៣- ប៉ាណ្វស ប៊ិតតែង ម៉ាត់ ត្រគ់ អ្ន អន់តក់ ផា បក់ តែង អង់កក់ ប៉ៃរ តាឡ្វះ ចាក អន់ទ្រួល ល្វ ត្រគ់ ប៉ានិត ហៃ ទ្រង តែង ម៉ាត់ ផា កាន ណោះ កាន អា ត្រគ់ បើក សាញ៉ា បៃិង សាម៉ា លើ លឹក តី សាម៉ា កេះណោះ តះ សាម៉ា ល្វ ប៉ាន់ថយ អន់ ពឹកៗ រ៉េះ បៃិង សាម៉ា បៃិត ភ្យឺ អន់ បក់ តែង អង់កក់ ឡាក់ ប៉ៃរ តាឡ្វះ អន់ទ្រួល ណោះ អ្ន អន់តក់ ពិន អន់ អ៊ែ តាឡ្វះ អន់ទ្រួល កេះ ។ ផា បក់ តែង ម៉ាត់ ប៉ប៉ ទ្រង ប៉ាគ់ ម៉ាត់ ទី កាន ឡុត ម៉្វត្វ អៀ លើ ទី កាន ណោះ កាន អា ត្រគ់ ប៉ប៉ សាញ៉ា តែង សាំងអៀ្យា លើ ប៉ាឡាង អំប៉ាង តី សាំងអៀ្យា ឡាច់ តែង ឡឹង អន់ ព្វ អ្ន អន់តក់ ផា បើ តាន៎ តាឡ្វះ អន់ទ្រួល ទី អុះ ។

៤-ផះ តាឡ្វះ ណោះ ត្រគ់ ជិះ ប្រ៉ាល់ ៗ បៃិត ល្វ គម អន់ ទី តាវ៉ាង៉ អ្យាង បៃិត ម៉ោញ ម៉ុត ។

៥-ផា ពឹង ទ្រង ណោះ អ្វ ទី ព្វ គួស សាញ៉ា ញ៉ា ប៉ាណ្វស ប៊ិតតាឡ្វះ ចាក ពឹង ទ្រង ម៉ោញ បៃិង ណារ្គ ទី ផា កាន តាឡ្វះ ណោះ អ្វ ប្រ៉ែគ៎ អន់ ទី កាន ខគ់កាំលើ ប្រ៉ែគ៎ អន់ ប៉ាណាប កា ព្វ អន់ទៀគ ណារ្គ ឡាក់ ប៊ុច តះ ប៉ាគ់ ណោះ ប៉ាគ់ អា ។

៦-ប៉ាគ់ តាឡ្វះ រ៉ាវ៉ាច់ កេះ ប៉ាណ្វស ប៊ិតត្រគ់ ប្រ៉ែគ៎ រ៉េះ បៃិង សាម៉ា ណារ្គ ភ្យឺ អន់ អ្ន អន់តក់ ឡាកោ អ៊ែ ម៉ុត ពឹង ទ្រង ត្រគ់ ចាក ប្រាន កេះ ។

៧-ផា ទ្រង អន់ដា ទី ទ្រង តះ ប៉ាគ់ ណោះ ប៉ាគ់ អា អៀង ហះ កា ទ្រង ម៉ោញ ទី ទ្រង តះ អៀង ម៉្វត ឡុត ផះ ជិះ ពឹង ទ្រង ចំ ម៉ោញ ប្រ៉ាល់ ឡឹង ព្វ ឃឺ អ្វ ត្រគ់ កាន តាឡ្វះ ចាក អន់ទ្រួល អុះ ។

## ➢ កាន ព្វ អ្វ អន់ តាឡ្វះ អន់ទ្រួល ទី ឡាក់ កា តែង អន់តេះ អ៉ា :

- តាឡ្វះ ម៉ោញ ទង បៃ៉ង ជួ ( តាឡ្វះ អញ៉ស្រំ ល្វ ឡុត ព្វ ផះ តាឡ្វះ កេះ )

- ហះ ចារ ទី សាញ៉ា អ្វ អន់ តាឡ្វះ អន់ទ្រួល
- ហះ ទ្រង កោគ លើ ផះ ហារ ច្រាំង ផា ទ្រង ទី សាញ៉ា ព្វ រែក ពឹង អន់តិគ័ អ្វ ទី ម៉្វត្វ ឡុត ណោះ ចឹង តាឡ្វះ ទី ។
- ក្យាម៉ ទ្រង តះ ទ្រង អៀង សាឡ្វះ លើ ទ្រង រ៉ាផល់
- ហះ ទ្រង ជឹរ ច្រាំង ទ្រង អង់អ្យាគ័ លើ ទ្រង ទី សាញ៉ា ព្វ អន់ ជិះ ពីកៗ
- ពឹង តាទរ លើ ផះ ជឹរ ច្រាំង
- ហះ ចារ ព្វ ផះ ប្រ៉ែគ័ លើ ផះ ប៉ាយ៉ាម៉ ទ្រង
- ក្យាម៉ លើ ហះ ឡាណុច ទ្រង អន់ ប៉ាណ្វស ចាក ជុង ឃ្លង
- អន់តេះ តាំទរ លើ ពឹង ត្រោម តេះ
- ផា ហៃ គ្លួបសោប អ្វ ស្វរ សាឡ្វះ រ៉ុំច ប៉្លែង តីស ផះ ប៉្លែង អ៊ិត លើ តី ទ្រង តេះ កាបក់
- ក្យាម៉ លើ ហះ ទ្រង ទី ឡុត អុញ ឃ្លង ឡាក់ ព្វ អ្វ បឹង ញ៉ា
- ពឹង ទ្រង ទី ទៀក លែប ។

## ច/ ករណីគ្រោះថ្នាក់ និងស្លាប់ដោយចរាចរណ៍
## ច/ កាន ខក់កាំ រ៉ា គែត ឌី ប្រមុក គណូប

<u>យោងតាម</u> ៖

- ក្រសួងមហាផ្ទៃអំពាវនាវដល់ប្រជាពលរដ្ឋអោយបង្កើនការគោរពច្បាប់ចរាចរណ៍។
- ជាតិស្រវឹង និងគ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់ចរាចរណ៍ និង ការបាត់បង់ជីវិតមនុស្ស
- <u>ប្រសាសន៍ឯកឧត្តមត្រាំ អ៊ីវតឹក បញ្ជាក់ពីគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជា ៖</u>
  ការស្លាប់និងរបួសស្នាម ដោយគ្រោះថ្នាក់ចរាចរណ៍ គឺជាបញ្ហាចំបង និងកំពុងកើនឡើងចំពោះសុខភាព សាធារណៈ។
- ប្រម៉ាង  យ៉ាគ់ ត្រាំ អ៊ីវតឹក ហាយ គិត កាន ខក់កាំ ទឹង កាំពុចៀ ៖

- ករណីគ្រោះថ្នាក់ចរាចរណ៍ផ្សេងៗ ក្នុងឆ្នាំ ២០១១

  ក្នុងឆ្នាំ ២០១១ គ្រោះថ្នាក់ចរាចរណ៍ មានច្រើនករណីណាស់ ប៉ុន្តែក្នុងនេះ យើងបានដកស្រង់តែករណីមួយចំនួន ដូចខាងក្រោម៖

## ករណីគ្រោះថ្នាក់ចរាចរណ៍ផ្សេងៗ ក្នុងឆ្នាំ ២០១១

1. បើកម៉ូតូលឿនដល់ផ្លូវកោងបត់មិនទាន់ជ្រុលចង្កូតធ្លាក់ផ្លូវបាក់កស្លាប់
2. មួយចេញពីហូបការ មួយចេញពីក្លឹបស្រវឹងធ្លាក់ភ្នែកបើករថយន្តបុកគ្នា
3. ស្រវឹងធ្លាក់ភ្នែកបោះពួយឡើងទ្រូងផ្លូវទៅបុកបង្គោលភ្លើងបាក់១ដើម
4. រថយន្ត2គ្រឿងបុកគ្នាឆេះនៅសល់តែគ្រោងឆ្អឹង
5. យុវជនម្នាក់ជិះម៉ូតូបុកជាមួយរថយន្តកុងតឺន័រស្លាប់ភ្លាមៗ
6. រថយន្តដឹកសាំងបើកលឿនធ្លាក់ផ្លូវក្រឡាប់កៀបអ្នកបើកបរស្លាប់
7. រថយន្តដឹកដីកែច្នៃបុកម៉ូតូពេញទំហឹងមនុស្សជាប់ក្រោមរថយន្ត
8. គ្រោះថ្នាក់ចរាចរណ៍រថយន្តបុកម៉ូតូឆ្លងថ្នល់ស្លាប់ស្ត្រីម្នាក់ក្មេងស្ត្រី2នាក់រងរបួសធ្ងន់
9. បើកវ៉ាគ្នាជាន់ហ្វ្រាំងរអិលចូលស្រែដេកលើសន្ទូងក្បែរផ្លូវ
10. ម៉ូតូ និងម៉ូតូបុកគ្នាស្លាប់ម្នាក់នៅនឹងកន្លែងរបួសធ្ងន់4នាក់
11. រថយន្តរ៉ឺហ្វ័របុកបង្គោលភ្លើងបន្តទៅបុកដើមក្រោកបាក់រលំ
12. រថយន្តទូរីសបុកម្ចាស់ម៉ូតូម៉ាករើវសន្លប់ចូលពេទ្យ
13. រថយន្តកាមរីបោះពួយបុកផ្ទះឧត្តមសេនីយ៍សួន ឈាងលី រួញក្រពឺតស្លាប់ម្នាក់
14. **ត្រាក់ទ័រសណ្តោងរឺម៉កដឹកធ្ងន់បើកចុះចំណោតក្រឡាប់ស្លាប់ម្នាក់**

**ដោយ ៖ អប្សរា** ថ្ងៃចន្ទ ទី១៤ ខែមិនា ឆ្នាំ២០១១ ម៉ោង ១៥:១០





យក្សឡោម

ខេត្តរតនគិរី ៖ ត្រាក់ទ័រសណ្តោងរ៉ឺម៉កមួយគ្រឿងដឹកសម្ភារសំណង់ និងកម្មករចំការចំនួន១១នាក់ ត្រូវក្រឡាប់ពេលបើកបរចុះចំណោតបណ្តាលឱ្យសង្កត់លើអ្នករួមដំណើរម្នាក់ស្លាប់ភ្លាមៗ ។ ហេតុការណ៍នេះបានកើតឡើងត្រង់ចំណុចផ្លូវចុះចំណោតអូរត្រាវ ស្ថិតក្នុងភូមិភ្នំ សង្កាត់យក្សលោម ក្រុងបានលុង វេលាម៉ោង១និង៣០នាទីរសៀលថ្ងៃទី១៣ មីនា ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា ត្រាក់ទ័រសណ្តោងរ៉ឺម៉កនោះ មានមនុស្សជិះ១១នាក់ អង្គុយពីលើសម្ភារសំណង់ មានស៊ីម៉ង់ត៍ ឥដ្ឋ និងខ្សាច់ ដែលបើកបរធ្វើដំណើរពីក្រុងបានលុង ឆ្ពោះទៅភូមិតាម៉ែនតូច ឃុំសាមគ្គី ស្រុកអូរជុំ តាមបណ្តោយផ្លូវជាតិលេខ ៧៨A ក្នុងទិសដៅពីលិចទៅកើត ដែលបើកបរដោយឈ្មោះផៃ ភេទប្រុស អាយុ៣៧ ឆ្នាំ ស្រុកកំណើតខេត្តកំពង់ចាម ហើយបានរត់គេចខ្លួនក្រោយពេលកើតហេតុ ។ ប្រភពពីកន្លែងហេតុការណ៍បានឱ្យដឹងថា ត្រាក់ទ័រសណ្តោងរ៉ឺម៉កនោះមកដល់ផ្លូវចុះចំណោតមានល្បឿនលឿនទំនងជាន់ហ្វ្រាំងមិនជាប់ ស្រាប់តែ

កន្ទុយរ៉ឺម៉កដែលផ្ទុកធ្ងន់បានរុញបុកតួរថយន្តខាងមុខ បណ្តាលឱ្យរេចង្កូតធ្លាក់ស្នាមភ្លោះខាងឆ្វេងជាចំណុចផ្លូវកោង ហើយមនុស្សដែលជិះលើនោះនាំគ្នាលោតប្រសាចចុះមកដី តែជាអកុសលមនុស្សម្នាក់លោតទៅខាងឆ្វេងចូលស្នាមភ្លោះ ត្រូវក្បាលរបស់ត្រាក់ទ័របុកដើមទ្រូងផ្ទប់ប្រឡាយ បណ្តាលឱ្យស្លាប់នៅនឹងកន្លែង ក្រៅពីនោះពុំមានរងគ្រោះថ្នាក់អ្វីទេ ។

ប្រភពពីប៉ូលិសក្រុងបានលុងបានឱ្យដឹងថា អ្នករងគ្រោះស្លាប់ឈ្មោះលាប អាយុប្រហែល៣៥ឆ្នាំ រស់នៅឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង មកស្នាក់នៅធ្វើចំការនៅភូមិតាម៉ែនតូច ឃុំសាមគ្គី ស្រុកអូរជុំ ។ បន្ទាប់ពីកើតហេតុ ប៉ូលិសក្រុងបានលុងបាននាំយករថយន្តស្ទូចអូសយកត្រាក់ទ័រសណ្តោងរ៉ឺម៉ក ដែលក្រឡាប់នោះមករក្សាទុកនៅអធិការដ្ឋានក្រុង និងដឹកសាកសពទៅតម្កល់ទុកនៅវត្តភូមិថ្មី (រស្មីសាមគ្គី) រង់ចាំសាច់ញាតិមកទទួល។ ទាក់ទិននឹងហេតុការណ៍នេះពុំមានការបំភ្លឺណាមួយដល់ប៉ូលិសអំពីអត្តសញ្ញាណរបស់ម្ចាស់ត្រាក់ទ័រនោះទេ ៕

## 15. ជិះម៉ូតូអត់ពាក់មួកសុវត្ថិភាពបុករទេះអេតចាយរបួសធ្ងន់ធ្ងរ

ដោយ ៖ **អប្សរា** ថ្ងៃពុធ ទី១០ ខែសីហា ឆ្នាំ២០១១ ម៉ោង ១០:៣៤



## យុវជនម្នាក់ស្រវឹងស្រាជិះម៉ូតូអត់ពាក់មួកសុវត្ថិភាពបុករទេះរុញអេតចាយ

រាជធានីភ្នំពេញ ៖ យុវជនម្នាក់ស្រវឹងស្រាជិះម៉ូតូអត់ពាក់មួកសុវត្ថិភាពបុករទេះរុញអេតចាយ បណ្ដាលឱ្យម៉ូតូដួលបោកក្បាលលើថ្នល់រងរបួសធ្ងន់ កាលពីវេលាម៉ោង១២និង២៩នាទីរំលងអធ្រាត្រឈានចូលថ្ងៃទី១០ សីហា ២០១១ នៅតាមបណ្ដោយមហាវិថីព្រះមុនីវ៉េត ទល់មុខពហុព្យាបាលវិសាលសុខស្ថិតក្នុងសង្កាត់ផ្សារដើមគ ខណ្ឌទួលគោក។

ប្រភពព័ត៌មានពីកន្លែងកើតហេតុបានឱ្យដឹងថា យុវជនម្នាក់ឈ្មោះ សុទ្ធ សិទ្ធិ អាយុ២៥ឆ្នាំ មានស្រុកកំណើតនៅស្រុកគិរីវង់ ខេត្តតាកែវ ត្រូវជាកូនរបស់លោកសុខ សែម នាយរងប៉ុស្តិ៍បឹងព្រលឹត បានជិះម៉ូតូម៉ាកវេវ៉ ពណ៌ក្រហម ពាក់ស្លាកលេខ ឃ-៥៩៦៥ ភព១ តាមបណ្ដោយមហាវិថីព្រះមុនីវ៉េត ក្នុងទិសដៅពីកើតឆ្ពោះទៅលិច ខណៈមកដល់មុខពហុព្យាបាលវិសាលសុខស្រាប់តែជ្រុលទៅបុករទេះអេតចាយ បណ្ដាល ឱ្យម៉ូតូដួល ចំណែកអ្នកបើកបរអត់ពាក់មួកការពារសុវត្ថិភាពបានបោកក្បាលទៅក្រោយរងរបួសធ្ងន់។

ពេលឃើញម៉ូតូ ដួលរងរបួសបែបនេះ ធ្វើឱ្យអ្នកអូសរទេះអេតចាយដែលដួលរងរបួសស្រាលដែរនោះ ក៏លើករទេះអូសរត់ចេញបាត់យ៉ាងប្រញាប់ប្រញាល់ នៅសល់តែអ្នកបើកបរម៉ូតូរងរបួសធ្ងន់ ត្រូវគេចាត់បញ្ជូនទៅព្យាបាលនៅគ្លីនិកគឹម សុង ផ្សារដេប៉ូ ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ទៀតនោះគឺពេលយកទៅដល់គ្លីនិក ជនរងគ្រោះមិនព្រមឱ្យគ្រូពេទ្យធ្វើការព្យាបាលទេ ចំណែកឪពុករបស់ជនរងគ្រោះក៏បានទៅដល់គ្លីនិក

ដែរ ឃើញស្ថានភាពធ្ងន់ធ្ងរបែបនេះ គ្រូពេទ្យបានបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត។
ប៉ូលិសបានយកម៉ូតូជនរងគ្រោះទៅរក្សាទុកនៅប៉ុស្តិ៍រដ្ឋបាលផ្សារដើមគ ដើម្បីរក្សាទុកប្រគល់ឱ្យជន
រងគ្រោះវិញ ។ នេះជាករណីគ្រោះថ្នាក់ដោយសារអ្នកបើកបរអត់ពាក់មួកការពារសុវត្ថិភាព ទើបរងរបួសធ្ងន់បែបនេះ៕

## 16. ជនជាតិគ្រឹង ២នាក់ ត្រូវរថយន្តក្រុមហ៊ុនកិនថ្មសៀងហៃបុកស្លាប់

ដោយ : មនោរម្យ (ថ្ងៃទី 30 មិថុនា 2010,04:39:PM)



សពបុរសអ្នកបើកបរម៉ូតូស្លាប់នៅកន្លែងកើតហេតុ

រតនគីរី ៖ រថយន្តរបស់ក្រុមហ៊ុនសៀងហៃ (កិនថ្ម) ធ្វើផ្លូវនៅស្រុកកូនមុំខេត្តរតនគីរី បានបើកបុកម៉ូតូសង់កូរ៉េ ១ គ្រឿង ជិះឌុបគ្នាពីរនាក់ស្លាប់ទាំងពីនាក់គួរឲ្យរន្ធត់ ។ ហេតុការគ្រោះថ្នាក់ចរាចរណ៍នេះកើតឡើងកាលពីម៉ោង ៩យប់ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១០ នៅម្តុំភូមិផ្សើក ឃុំតាអង ស្រុកកូនមុំខេត្តរតនគីរី ។

ប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថា ម៉ូតូសង់កូរ៉េពណ៌ក្រហមគ្មានស្លាកលេខបានជិះឌុបគ្នា ២នាក់ បានបើកចេញពីទិសខាង

ត្បូងទៅជើង លុះមកដល់ចំណុចកើតហេតុម្តុំចំការឈ្មោះសុវណ្ណ ស្ថិត
នៅភូមិផ្សើក ឃុំតាអង ក៏វាក់អីជាមួយ និងរថយន្ត ១គ្រឿង របស់ក្រុម
ហ៊ុនសៀងហៃ (គិនថ្ន) បុកចំពីមុខយ៉ាងពេញទំហឹងបណ្តាលឲ្យអ្នក
បើកម៉ូតូស្លាប់នៅនឹងកន្លែងភ្លាមៗ ហើយអ្នកជិះខាងក្រោយរបួសធ្ងន់ ហើយស្លាប់
ពេលបញ្ជូនដល់មន្ទីរពេទ្យខេត្ត ។

ប៉ូលិសចរាចរណ៍ខេត្តបានឲ្យដឹងថា ហេតុការគ្រោះថ្នាក់ចរាចរណ៍
នេះ គឺបណ្តាលមកពីម៉ូតូបើកពេលយប់ពុំមានភ្លើងចង្កៀងគឺ ប្រើតែភ្លើងគោមជំនួស
ទើបធ្វើឲ្យអ្នកបើកបររថយន្តច្រឡំបានជាបង្កឲ្យមានគ្រោះថ្នាក់បាត់បង់ជីវិត ។ ប៉ូលិស
បានបញ្ជាក់ថា ជនរងគ្រោះបាត់បង់
ជីវិតទាំងពីនាក់នោះម្នាក់ឈ្មោះ សាម៉េត មួន ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិគ្រឹង
ជាអ្នកបើកបរម៉ូតូ ។ ម្នាក់ទៀតដែលជិះខាងក្រោយឈ្មោះ
រង៉ាវ វេន ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិគ្រឹងនៅភូមិជាមួយគ្នា ។
ឯអ្នកបើបររថយន្តពុំមានរងរបួសទេគឺឈ្មោះ អ៊ង យ៉ិន ភេទប្រុស អាយុ ៣៤ឆ្នាំ
មុខរបរបើកបររថយន្តឲ្យក្រុមហ៊ុនគិនថ្ន (សៀងហៃ) នៅភូមិ១
ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគីរី ។ រថយន្តរបស់ក្រុមហ៊ុនម៉ាក ហ្វូតពណ៌
ប្រផេះពីបាំងពាក់ស្លាកលេខ AT102-0060 ។ បន្ទាប់ពីប៉ូលិសចរាចរណ៍បានធ្វើការ
វាស់វែងរួចហើយឃើញថា ម៉ូតូជាអ្នកខុសហើយបាននាំយកម៉ូតូ និងរថយន្តបញ្ជូនមក
រក្សាទុកនៅស្នងការដ្ឋាននគរបាលខេត្ត ដើម្បីដោះស្រាយ ។ រីឯសាកសពទាំង ២នាក់
ប៉ូលិសបានប្រគល់ឲ្យសាច់ញាតិរបស់សពយកទៅធ្វើបុណ្យតាមប្រពៃណី ៕

# ក្រសួងមហាផ្ទៃអំពាវនាវដល់ប្រជាពលរដ្ឋអោយបង្កើនការគោរពច្បាប់ចរាចរណ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១២៧០ សជណ

**សេចក្ដីអំពាវនាវ**

រហូតមកដល់បច្ចុប្បន្ននេះ សមត្ថកិច្ចគ្រប់ថ្នាក់បាននឹងកំពុងជម្រុញការផ្សព្វផ្សាយអប់រំ និងរឹតបន្តឹងការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកយ៉ាងខ្លាំងក្លា ធ្វើឲ្យអ្នកប្រើប្រាស់ផ្លូវភាគច្រើនលើសលប់មានការយល់ដឹងចូលរួមគោរពប្រតិបត្តិច្បាប់ចរាចរណ៍ផ្លូវគោក ជម្រុញឲ្យសណ្ដាប់ធ្នាប់ចរាចរណ៍កាន់តែមានភាពល្អប្រសើរជាលំដាប់ និងបានរួមចំណែកកាត់បន្ថយអគ្រោះថ្នាក់មួយចំនួន ។

ប៉ុន្តែទោះបីជាយ៉ាងនោះក៏ដោយ ក៏សមត្ថកិច្ចបានកត់សម្គាល់ឃើញថា នៅតែមានការកើតឡើងដោយចេតនានូវករណីល្មើសច្បាប់ចរាចរណ៍ផ្លូវគោកមួយចំនួនដូចជា ការមិនគោរពសញ្ញាចរាចរណ៍ ការបំពាក់ស្លាកលេខយានយន្តមិនត្រឹមត្រូវ ការមិនបំពេញកាតព្វកិច្ចបង់ពន្ធយានយន្ត ការបើកបរលើសល្បឿនកំណត់ ការបើកបរក្រោមឥទ្ធិពលនៃជាតិស្រវឹង ការដឹកលើសកំរិតកំណត់ ការកែតម្រូវលក្ខណៈបច្ចេកទេសយានយន្តខុសច្បាប់ ការបើកបរដោយគ្មានប័ណ្ណបើកបរ ការរំលោភសិទ្ធិអាទិភាពនៃការប្រើប្រាស់ផ្លូវថ្នល់ ដែលជាបច្ច័យអវិជ្ជមានបង្កឲ្យបាត់បង់សណ្ដាប់ធ្នាប់ចរាចរណ៍ និងបង្កឲ្យអគ្រោះស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅតែមានកំរិតខ្ពស់ប៉ះពាល់ដល់កិត្យានុភាពជាតិ និងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

ដើម្បីលុបបំបាត់ករណីខាងលើ ក្រសួងមហាផ្ទៃសូមអំពាវនាវដល់អ្នកប្រើប្រាស់ផ្លូវសាធារណៈគ្រប់រូបត្រូវបង្កើនស្មារតីប្រុងប្រយ័ត្ន គោរពប្រតិបត្តិច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ពិសេស មន្ត្រីរាជការ និងមន្ត្រីកងកម្លាំងប្រដាប់អាវុធ ត្រូវមានកាតព្វកិច្ចធ្វើជាគំរូឈានមុខក្នុងការគោរពប្រតិបត្តិច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកឲ្យបានខ្ជាប់ខ្ជួន សំដៅធ្វើឲ្យសណ្ដាប់ធ្នាប់ចរាចរណ៍កាន់តែបានប្រសើរ កាត់បន្ថយអគ្រោះថ្នាក់ចរាចរណ៍ជាអតិបរិមានាំមកនូវសុវត្ថិភាពនិងសុភមង្គលជូនប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល ។

ក្រសួងមហាផ្ទៃសង្ឃឹមជឿជាក់ថា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋគ្រប់រូបនឹងប្រតិបត្តិតាមសេចក្ដីអំពាវនាវនេះគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១១*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈបញ្ជាការដឹកនាំ**
**បញ្ជាការដ្ឋានពិនិត្យការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក**

ស ខេង

Prepared for first online distribution in March 2015 by


អងគការសហការអនដរជារិកម្ពុជា

International Cooperation Cambodia

P.O. Box 612

Phnom Penh, Cambodia

Tel: 092-469-934 / 075-974-029

http://www.icc.org.kh

info@icc.org.kh



This work is dual licensed under either of these Creative Commons licenses:

- Attribution-ShareAlike 4.0 International License.(Cc-BY-SA) To view a copy of this license, visit http://creativecommons.org/licenses/by-sa/4.0/.
- Attribution-NonCommercial-ShareAlike (CC BY-NC-SA) To view a copy of this license, visit http://creativecommons.org/licenses/by-nc-sa/4.0/.

**You are free to:**

**Share** — copy and redistribute the material in any medium or format
**Adapt** — remix, transform, and build upon the material
for any purpose, even commercially.
The licensor cannot revoke these freedoms as long as you follow the license terms.

**Under the following terms:**

**Attribution** — You must give appropriate credit, provide a link to the license, and indicate if changes were made. You may do so in any reasonable manner, but not in any way that suggests the licensor endorses you or your use.

**ShareAlike** — If you remix, transform, or build upon the material, you must distribute your contributions under the same license as the original.
**No additional restrictions — You may not apply legal terms or technological measures that legally restrict others from doing anything the license permits.**